# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ០៦៥៩........ក.ស.ភ.

ថ្ងៃ ចន្ទ ៩កើត ខែអាសាឍ ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ កក្កដា គ.ស.២០១៧

## សេចក្តីជូនដំណឹង(លើកទី២)
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារសាងសង់ច្រាំងទន្លេប្រវែង៥៦០ម
## នៅប្លង់B នៃចំណតផែកុងតឺន័រថ្មី (LM17)

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស ( គិតទាំងសហគ្រាសឯកត្តបុគ្គល )ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា : កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារសាងសង់ច្រាំងទន្លេប្រវែង៥៦០ម នៅប្លង់B នៃចំណតផែកុងតឺន័រថ្មី (LM17) ។

កំពង់ផែស្វយ័តភ្នំពេញបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញដែលមានអាសយដ្ឋានអគារលេខ៦៤៩វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី**ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៧** តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១០ ៤៤៤.៥៧១ ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម **ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ វេលាម៉ោង ១៤:៣០** ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង ១៤:៣០. ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧** ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

PHNOM PENH AUTONOMOUS PORT

**ណែម_ធីម**

ចម្លងជូន ៖
- -អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- -អង្គភាពប្រឆាំងអំពើពុករលួយ